សុន្ទរកថារបស់ **លោក តាម៉ាមីស៊ឺ ស៊ីនីជិ**
លេខាទីមួយ ប្រធានផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ
ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីសម្ពោធអគារសិក្សាថ្មីនៅសាលាបឋមសិក្សារលាប
ពោធិ៍សាត់ ៣០ កញ្ញា ២០១៣

**សូមគោរព ឯកឧត្តម ណុះ ស្លេះ អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា!**
**សូមគោរព ឯកឧត្តម ម៉ាក់ រ៉ា អភិបាលរងខេត្តពោធិ៍សាត់!**
**សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយ ដើម្បីចូលរួមក្នុងពិធីសម្ពោធនៅសាលាបឋមសិក្សារលាបនៅថ្ងៃនេះ ជាមួយនឹងវត្តមានរបស់ឯកឧត្តម ម៉ាក់ រ៉ា អភិបាលរងខេត្តពោធិ៍សាត់។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តមអភិបាលរងខេត្ត និងបុគ្គលិករបស់ឯកឧត្តមដែលបានរៀបចំឲ្យមានពិធីនេះឡើង។

ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលពិធីសម្ពោធនេះត្រូវបានធ្វើឡើងក្នុងឱកាសដ៏ពិសេសនៃឆ្នាំ២០១៣នេះដែលជាឆ្នាំខួបអនុស្សាវរីយ៍ទី៦០នៃទំនាក់ទំនងមិត្តភាពជប៉ុន-កម្ពុជា។

ក្នុងរយៈពេលពីរទសវត្សចុងក្រោយនេះបន្ទាប់ពីសង្គ្រាមស៊ីវិលត្រូវបានបញ្ចប់ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងកិច្ចកសាង និងអភិវឌ្ឍន៍ប្រទេសឡើងវិញហេតុបានក្លាយជាប្រទេសមួយដែលមានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងចំណោមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចំរើនក្នុងតំបន់អាស៊ាន។ ជាមួយគ្នានេះផងដែរ វិស័យអប់រំបានបន្តរីកចំរើនទាំងបរិមាណ និង គុណភាពពីមួយឆ្នាំទៅមួយឆ្នាំ។

ខ្ញុំសូមធ្វើការកោតសរសើរ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល កម្ពុជា ក្នុងការកែលម្អវិស័យអប់រំ។ ដោយទទួលស្គាល់ពីសារៈសំខាន់ នៃការអប់រំថាជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនោះ រដ្ឋាភិបាល ជប៉ុន បាននិងកំពុងបន្តផ្តល់ជំនួយ ឧបត្ថម្ភរបស់ខ្លួនដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា តាមរយៈការជួយសាងសង់ សាលារៀន ក៏ ដូចជាបណ្តុះបណ្តាលគ្រូបង្រៀនជាដើម។

បច្ចុប្បន្ន ចំនួន សាលាបឋមសិក្សាក្នុងប្រទេសកម្ពុជាមានប្រមាណ៦,៩០០ ដែលក្នុងនោះ៧៥ ភាគរយត្រូវដាក់ឲ្យដំណើរការពីរវេន។ ជាងនេះទៅទៀត អគារសិក្សាខ្លះៗនៃសាលាទាំងនេះបានហួសអាយុកាលប្រើប្រាស់ហើយត្រូវធ្វើការសាងសង់ឡើងវិញដើម្បីសុវត្ថិភាពរបស់សិស្សានុសិស្ស។

ខ្ញុំបានទទួលដំណឹងថា សិស្សានុសិស្សនៅសាលាបឋមសិក្សារលាបនេះត្រូវអង្គុយប្រជ្រៀតគ្នារៀននៅក្នុងថ្នាក់រៀននៃអគារឈើចាស់ទ្រុឌទ្រោមដែលក្នុងនោះបន្ទប់រៀន៣ត្រូវបិទលែងដំណើរការដោយសារមូលហេតុសុវត្ថិភាព។ ពិសេសនៅរដូវវស្សា ដំបូលអគារបែកបាក់ធ្លុះធ្លាយមានទឹកស្រក់ធ្លាក់មកលើសិស្សានុសិស្ស ធ្វើឲ្យមានការលំបាកក្នុងការប្រមូលផ្តុំអារម្មណ៍ យកចិត្តទុកដាក់ក្នុងការរៀនសូត្រផងដែរ។ ឥឡូវនេះអគារសិក្សាថ្មីដែលមាន៥បន្ទប់ និងបន្ទប់អនាម័យ បានសាងសង់រួចរាល់ហើយ ហើយក្មួយៗសិស្សានុសិស្សទាំងអស់អាចសិក្សានៅក្នុងអគារសិក្សាថ្មីនេះប្រកបដោយសុវត្ថិភាព និង ផាសុខភាព។

ខ្ញុំសង្ឃឹមថាសិស្សានុសិស្សនៃសាលាបឋមសិក្សារលាបទាំងអស់នឹងខិតខំប្រឹងប្រែងរៀនសូត្រនៅក្នុងថ្នាក់រៀនថ្មីដែលមានបរិស្ថានសិក្សាល្អប្រសើរនេះ ហើយនឹងជួយថែរក្សាអគារនេះឲ្យបានគង់វង្សល្អទុកជានិមិត្តរូបដ៏យូរអង្វែងមួយនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសំដែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើឲ្យគម្រោងនេះដំណើរការទៅបានដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនកម្ពុជា និងប្រជាជនជប៉ុន។

សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!